*Kurien, J., So, N., and Mao, S.O. 2006*. Cambodia's Aquarian Reforms: the Emerging Challenges in Policy and Research. Inland Fisheries Research and Development Institute (IFREDI), Phnom Penh, Cambodia. (Available at www.ifredi.org)

*MAFF-CNMC. 2003*. National Sector Review 2003: Fisheries Management. Ministry of Agriculture, Forestry and Fisheries (MAFF) in association with Cambodia National Mekong Committee (CNMC). 15 p.

*National Institute of Statistics. 2005*. National Account of Cambodia 1993-2004. Ministry of Planning, Phnom Penh.

*Rab, M.A., Hap, N., Ahmed, M., Keang, S.L. and Viner, K. 2005*. Socioeconomics and Values of Resources in Great Lake - Tonle Sap and Mekong - Bassac Area: Results from a Sample Survey in Kampong Chhnang, Siem Reap and Kandal Provinces. WorldFish Center, Penang, Malaysia. (Available at www.ifredi.org)

## សារៈសំខាន់នៃការប្រកបរបរចិញ្ចឹមជីវិតនិង តំលៃនៃធនធានជលផលនៃបឹងទន្លេសាប

**ហាប ណាវី**

**រតនា ឈឿនផាកឌី**

**ចន គុរាន**

២០០៦

បោះពុម្ពផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទ ទឹកសាប (IFReDI) នៃនាយកដ្ឋានជលផល
អាសយដ្ឋាន : អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Hap, N.,Chuenpagdee, R. and Kurien, J. 2006. Livelihood Importance and Values of Tonle Sap Lake Fisheries. Inland Fisheries Research and Development Institute, Phnom Penh, Cambodia. 8 pp.

ឯកសារគោលនយោបាយនេះត្រូវបានរៀបរៀងឡើង ជាផ្នែកមួយនៃជំនួយបច្ចេកទេសសម្រាប់ការកសាង សមត្ថភាព នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាបដែលបានអនុវត្តដោយមជ្ឈមណ្ឌលត្រី ពិភពលោក និងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (TA 4563-CAM).

នេះមិនមែនជាការបោះពុម្ពផ្សាយជាផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទេ ហើយទស្សនៈដែលបាន ឆ្លុះបញ្ចាំងនៅទីនេះ មិនទាក់ទងនឹងធនាគារអភិវឌ្ឍន៍អាស៊ីឡើយ។



picture by Hap Navy

**វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប**



**ដើម្បីអភិវឌ្ឍន៍ជលផលទឹកសាបកម្ពុជាដោយនិរន្តរភាព**

**ឯកសារគោលនយោបាយ**

# សារៈសំខាន់នៃការប្រកបរបរចិញ្ចឹមជីវិតនិងតំលៃ នៃធនធានជលផលនៃបឹងទន្លេសាប

**ហាប ណាវី, រតនា ឈឿនផាកឌី, ចន គុរាន**

ជលផលគឺជាធនធានមួយយ៉ាងសំខាន់សំរាប់ការរស់នៅរបស់ប្រជាជនកម្ពុជាជាយូរលង់ណាស់មកហើយ។ មានប្រជាជនសរុបច្រើនជាងមួយលាននាក់ ជាពិសេសប្រជាជន ដែលរស់នៅតំបន់បឹងទន្លេសាប ដែលពឹងផ្អែកទៅ លើធនធានជលផល និងធនធាន វារិជាតផ្សេងៗទៀតសំរាប់ជាម្ហូបអាហារ ប្រាក់ចំណូល និង ជារបរចិញ្ចឹមជីវិត។ អត្ថបទនេះបង្ហាញឱ្យឃើញពីសារៈសំខាន់ជាក់ស្តែងមួយដែលបានមកអំពីធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីនៃ ធនធានវារិជាតនៃបឹងទន្លេសាប។ ក៏ប៉ុន្តែតំលៃសរុបនៃប្រព័ន្ធអេកូឡូស៊ីនេះ ជាពិសេសចំពោះប្រជាជនដែលរស់ នៅដោយពឹងផ្អែកជាចំបងនិងទាំងស្រុងទៅលើធនធានទាំងអស់នោះនៅតែមិនទាន់ដឹងពិតប្រាកដពីអត្ថប្រយោជន៍ និង សារៈសំខាន់របស់ធនធានទាំងនោះនៅឡើយ។

## ការធ្វើនេសាទនៅតំបន់បឹងទន្លេសាប

មានការសិក្សាមួយចំនួនបានធ្វើឡើងដើម្បីលើកកំពស់នូវការយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ចសង្គម និងការប្រកប របរចិញ្ចឹមជីវិតរបស់សហគមន៍នានានៅតំបន់បឹងទន្លេ សាប។ របាយការណ៍មួយដែលបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៩៥ និងមានចំណងជើងថា "**ការវាយតំលៃសេដ្ឋកិច្ចសង្គមនៃផលចាប់ជលផលទឹកសាបរបស់ប្រទេសកម្ពុជា**" (Ahmed *et al*.,1998) គឺជារបាយការណ៍មួយ ដែលគេបានយកមកធ្វើជាមូលដ្ឋានគ្រឹះញឹកញាប់បំផុត ដោយហេតុថា វាផ្តល់នូវការយល់ដឹងយ៉ាងស៊ីជំរៅអំពី ស្ថានភាពចរិត លក្ខណៈប្រជាសាស្រ្ត សកម្មភាពសេដ្ឋកិច្ច និង យុទ្ធសាស្រ្តនៃការប្រកបរបរចិញ្ចឹមជីវិតរបស់ ប្រជាជនជាង ៥០០០គ្រួសារដែលរស់នៅក្នុង៨ខេត្ត នៅក្នុង និងជុំវិញបឹងទន្លេ សាប និងទន្លេមេគង្គ-បាសាក់។ មានហេតុផលដែលគួរអោយជឿជាក់ថាចរិតលក្ខណៈ ខ្លះៗនៃអ្នកដែលពឹងផ្អែក ទៅលើធនធានជលផលមានការ ប្រែប្រួល ដោយសារកត្តាមួយចំនួនដូចជាកំនើនប្រជាជន ការអភិវឌ្ឍន៍សេដ្ឋកិច្ច សុខមាលភាពនៃប្រពន្ធ័វារីអេកូឡូស៊ី និង កំនែទំរង់នៃ គោលនយោបាយដែលទាក់ទង ទៅនិងវិស័យជលផលនាពេលថ្មីៗនេះ។ ការសិក្សាថ្មីមួយ ដែលមានទំរង់និងទំហំប្រហាក់ប្រហែលគ្នានឹងករណី សិក្សាមុននេះ គឺប្រាកដជា មានតម្រូវការចាំបាច់បំផុត។

ក៏ប៉ុន្តែ **តើអ្វីដែលយើងអាចនិយាយបានអំពីធនធានជលផលនៅតំបន់បឹងទន្លេសាប ដោយប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងរបាយការណ៍ផ្សេងៗ និង ការសិក្សានានាដែលមានស្រាប់?** ចំពោះប្រភពទិន្នន័យដែលបានមកពីរដ្ឋាភិបាល បានផ្តល់ជាព័ត៌មានថា ធនធានជលផលនៃតំបន់បឹងទន្លេសាបចូលរួមប្រហែលជា ៦០%នៃផលនេសាទទឹកសាបសរុប ឬចន្លោះពី ២០០.០០០ ទៅ ២១៨.០០០តោន ដែលមាន តំលៃប៉ាន់ស្មាន ស្មើនឹង ១៥០ ទៅ ២៥០លានដុល្លាអាមេរិច។ ច្បាប់ជលផលថ្មីបានអនុញ្ញាត្តិអោយអ្នកនេសាទជា លក្ខណៈគ្រួសារ ឬកិរិតតូច ធ្វើនេសាទនៅក្នុងបឹងទន្លេសាបពេញមួយឆ្នាំដោយមិនចាំបាច់សុំលិខិតអនុញ្ញាត្តិឡើយ។ រីឯការនេសាទទ្រង់ទ្រាយមធ្យមអាចធ្វើនេសាទតែនៅក្នុងចន្លោះពីខែតុលា

**គាំទ្រដោយ**

ADB

**ADB TA 4563-CAM**
ការកសាងសមត្ថភាព នៃវិទ្យាស្ថានស្រាវជ្រាវ
និងអភិវឌ្ឍន៍នេសាទទឹកសាប (វគ្គ២)

ដល់ខែឧសភា ព្រោះជាពេលដែលកំរិតទឹកក្នុងបឹងទន្លេសាបចាប់ផ្តើមស្រក និង តំបន់វាលលិចទឹករួមតូចទៅៗ។ ចំណែកការធ្វើនេសាទទ្រង់ទ្រាយធំ ឡូត៍នេសាទ គឺជានេសាទឧស្សាហកម្ម ដែលត្រូវអនុវត្តទៅតាមប្រព័ន្ធនៃការជួលដេញថ្លៃក្នុងរយៈពេលពីរឆ្នាំ ម្តង។

ក្រៅពីការប្រើប្រាស់ឧបករណ៍នេសាទ មានកត្តាផ្សេងៗទៀតជាច្រើនដែលបែងចែកភាពខុសគ្នារវាង ប្រភេទនេសាទនិមួយៗ ដូចជាទាក់ទងទៅនិងបរិមាណ និងការប្រើប្រាស់នៃផលចាប់ និងចំនួនគ្រួសារដែលចូលរួមទៅក្នុងសកម្មភាពនេសាទទាំងនោះ។ ការសិក្សាដែលបានធ្វើឡើងដោយ Ahmed *et al.*,(1998) បានប៉ាន់ស្មានថាផលចាប់ដែលបានមកពីការប្រើឧបករណ៍នេសាទជាលក្ខណៈគ្រួសារមានបរិមាណជាមធ្យមប្រហែលជា ៧០០គីឡូ ក្រាមក្នុងមួយឆ្នាំក្នុងមួយគ្រួសារ និង ផលចាប់ដែលបានមកពីឧបករណ៍នេសាទទ្រង់ទ្រាយមធ្យម គឺមានចំនួនច្រើន ជាងប្រហែលជា ៥ដង។

សមាមាត្រនៃផលចាប់របស់អ្នកនេសាទជាលក្ខណៈគ្រួសារ គឺសំរាប់ការប្រើប្រាស់សំខាន់ៗនៅក្នុងគ្រួសារមានកំរិតខ្ពស់ជាងគេ បើប្រៀបធៀបទៅនិងអ្នកនេសាទទ្រង់ទ្រាយមធ្យម។ ភាពខុសគ្នាចំបងបំផុតនៃសកម្មភាពនេសាទទាំងពីរខាងលើនេះ គឺចំនួនមនុស្សដែលចូលរួមក្នុងការធ្វើនេសាទ។ លទ្ធផលនៃការសិក្សាបានបញ្ជាក់ថា នៅក្នុងឆ្នាំ ១៩៩៥ មានប្រជាជនប្រហែលជា ៨៥.០០០គ្រួសារនៅក្នុងខេត្តសំខាន់ៗទាំង៥ ដែលស្ថិតនៅជុំវិញបឹងទន្លេសាប ខេត្តបាត់ដំបង សៀមរាប ពោធិសាត់ កំពង់ឆ្នាំង និងកំពង់ធំ គឺមានការចូលរួមយ៉ាងសកម្ម ក្នុងការធ្វើនេសាទ ហើយក្នុងនោះមានតែប្រហែលជា ៩.០០០គ្រួសារតែប៉ុណ្ណោះ ដែលធ្វើនេសាទជាលក្ខណៈមធ្យម។ បើគិតអំពីកំនែទំរង់វិស័យជលផលនាពេលថ្មីៗនេះវិញ ចំនួនគ្រួសារដែលចូលរួមក្នុងសកម្មភាពនេសាទ គឺហាក់ដូចជាមានការកើនឡើងជាលំដាប់។

## អ្នកនេសាទជាលក្ខណៈគ្រួសារនៅតំបន់បឹងទន្លេសាប

**តើអ្វីខ្លះជាចរិតលក្ខណៈនៃវប្បធម៌និងសង្គមរបស់អ្នកនេសាទគ្រួសារ ឬកំរិតតូចនៅក្នុងបឹងទន្លេសាប?** ការសិក្សាជាលក្ខណៈ ប្រជាសាស្រ្តនៃសហគមន៍នៅតំបន់បឹងទន្លេសាបបានសរសេរថាចំនួនគ្រួសារជាមធ្យម គឺមានចំនួន៦នាក់ ហើយភាគច្រើនបុរសគឺជាមេគ្រួសារ។ ជាងពីរភាគបីនៃសមាជិកគ្រួសារទាំងអស់ រួមមានស្រ្តី និងកូនក្មេង បានចូលរួមក្នុងទំរង់ការងារផ្សេងៗដែលទាក់ទងទៅនឹងការប្រមូលផល ការកែច្នៃ ឬទីផ្សាររបស់ត្រី និងការថែរក្សា និងជួសជុលឧបករណ៍នេសាទ។ រីឯផ្នែកជនជាតិវិញ ភាគច្រើននៃសមាជិកគ្រួសារ គឺមានខ្មែរ ចិន វៀតណាម និង ជនជាតិចាមមានភាគតិច។ ចំណែកការចូលសាលារៀន គឺនៅមានកំរិតទាបនៅឡើយ ដោយហេតុ ថាគ្រួសារភាគច្រើនរស់នៅក្នុងតំបន់ជនបទដាច់ស្រយាល និង អ្នកខ្លះទៀតសាងសង់ផ្ទះរបស់គេនៅលើនិងបណ្តែត ក្នុងទឹក។ នេះបង្ហាញឱ្យឃើញថា កំរិតវប្បធម៌របស់ពួកគេនៅមានកំរិតទាប និងទទួលបានការអប់រំតិចតួចនៅក្នុង នោះមានប្រហែលពី ២០ ទៅ ២៥% នៃសមាជិកគ្រួសារដែលមិនចេះអក្សរ។ ជាពិសេស អ្នកដែលមានកំរិតវប្បធម៌ទាបនោះ គឺសមាជិកគ្រួសារជាស្រ្តី ហើយរួមទាំងស្រ្តីដែលជាមេគ្រួសារផងដែរ។ នេះអាចបកស្រាយបាន មួយភាគថា មេគ្រួសារជាស្រ្តីតែងតែមានប្រាក់ចំណូលទាប និងស្ថានភាពសេដ្ឋកិច្ចខ្សោយ បើប្រៀបធៀបទៅនឹងគ្រួសារដែលមានបុរសជាមេគ្រួសារ។

ចំពោះការសិក្សាថ្មីមួយ ដែលធ្វើឡើងនៅឆ្នាំ ២០០៣ ដែលមានចំណង ជើងថា "**សេដ្ឋកិច្ចសង្គម និង តំលៃនៃធនធានជលផលនៅតំបន់បឹងទន្លេសាប និងទន្លេមេគង្គ-បាសាក់**" (Rab *et al.*, 2005) បានបែងចែកភាពខុសគ្នាបន្ថែមទៀត អំពីប្រជាជនដែលរស់នៅជុំវិញបឹងទន្លេសាប ទៅតាមកំរិតនៃការចូលរួមរបស់ពួកគេទៅក្នុងសកម្មភាពនេសាទ។ ប្រភេទភូមិអ្នកនេសាទ គឺសំដៅទៅលើភូមិដែលមានគ្រួសារពី ៨០ ទៅ ៩០% ដែលចាត់ទុកថាការធ្វើនេសាទជាមុខរបរចំបងរបស់ពួកគេ។ ចំពោះប្រភេទភូមិធ្វើស្រែវិញ គឺជាភូមិដែលមានគ្រួសារ យ៉ាងតិច ៨០% យកការធ្វើស្រែចំការជាមុខរបរចំបង។ ចំណែកឯ ប្រភេទភូមិនេសាទផងនិងធ្វើស្រែផង គឺជាភូមិដែលមានគ្រួសារពឹងផ្អែកទៅលើការធ្វើនេសាទនៅក្នុងរដូវវស្សា និង ធ្វើស្រែក្នុងរដូវប្រាំង។ ហើយមានស្ទើរតែគ្រប់គ្រួសារ ទាំងអស់នៅក្នុងភូមិនេសាទ និង ប្រហែលជា ៦៦%នៃគ្រួសាររស់នៅក្នុងភូមិនេសាទផង និង ធ្វើស្រែផង ដែលធ្វើនេសាទពេញមួយឆ្នាំ។ ម្យ៉ាងវិញទៀត នៅក្នុងប្រភេទភូមិធ្វើស្រែ មានជិតពាក់កណ្តាលនៃគ្រួសារទាំងអស់ ដែលធ្វើនេសាទក្នុងកំឡុងពេលរដូវបិទតែប៉ុណ្ណោះ ព្រោះថានៅក្នុងរយៈពេលនោះ ពួកគេមិនអាចធ្វើស្រែបានទេ ដោយសារនៅទីនោះមានកំរិតទឹកខ្ពស់។

ភាពខុសគ្នារបស់សហគមន៍ដែលពឹងផ្អែកទៅលើធនធានជលផលតាមប្រភេទភូមិនិមួយៗ បានផ្តល់នូវការយល់ដឹងស៊ីជំរៅផ្សេងៗទៀត។ ជាឧទាហរណ៍ ដូចមាននៅក្នុង (Rab *et al.*, 2005) បានបង្ហាញថា ទ្រព្យសម្បត្តិ កម្មសិទ្ធ និង កំរិតនៃបំណុល គឺមានភាពប្រែប្រួលទៅតាមប្រភេទភូមិនិមួយៗ។ មានគ្រួសារមួយចំនួននៅក្នុងភូមិនេសាទ គឺសាងសង់ផ្ទះរបស់ពួកគេនៅលើទូក ឬ លើទឹក នៅលើបែរត្រី និងបោះបង្គោលក្នុងទឹក ដោយហេតុថា ពួកគេគ្មានដីធ្លី។ ដូច្នេះហើយ តំលៃនៃផ្ទះរបស់ពួកគេ គឺមានតំលៃទាបជាងអ្នកដែលរស់នៅក្នុងភូមិធ្វើស្រែ។ ទោះបីជាយ៉ាងណាក៏ដោយគ្រួសារនេសាទមិនដូចគ្នានឹងគ្រួសារប្រកបរបរធ្វើស្រែឡើយ ព្រោះថាពួកគេទាមទារ នូវការវិនិយោគខ្ពស់ទៅលើឧបករណ៍សំភារៈបរិក្ខាសំរាប់ប្រកបមុខរបរនោះ ដូចជា ទូកសំរាប់ធ្វើនេសាទ និង ធ្វើដំណើរផ្សេងៗ ម៉ាស៊ីនភ្លើង ម៉ាស៊ីនកាណូត និង ទូរស័ព្ទជាដើម សំរាប់ការទិញលក់ និងកែច្នៃត្រី។ ភាគរយនៃការចំណាយរបស់ពួកគេទៅលើរបស់បរិភោគក៏មានភាពខ្ពស់ជាងគេផងដែរ បើប្រៀបធៀបទៅនឹងគ្រួសារនៅក្នុងប្រភេទភូមិនេសាទផងនិងធ្វើស្រែផង និងប្រភេទភូមិធ្វើស្រែសុទ្ធ។ ហេតុដូច្នេះហើយ អ្នកនេសាទ មានជំពាក់បំណុលគេច្រើនជាងអ្នកធ្វើស្រែ ហើយប្រភពនៃប្រាក់កម្ចីសំខាន់របស់ពួកគេ គឺ ខ្ចីពីបងប្អូន ឬ មិត្តភក្តិ អ្នកទិញលក់ត្រី និង អ្នករកស៊ីចងការប្រាក់នៅក្នុងភូមិ ក៏ប៉ុន្តែមិនមែនស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារឡើយ។

## ប្រភេទនៃមុខរបរជាច្រើន យុទ្ធសាស្រ្តនៃការប្រកបរបរចិញ្ចឹមជីវិត និងតួនាទីនៃយេនឌ័រ

គ្រួសារជាច្រើនដែលរស់នៅជុំវិញបឹងទន្លេសាបត្រូវបានបែងចែកដាច់ពីគ្នាទៅតាមប្រភេទនៃមុខរបរជាច្រើនរបស់ពួកគេ ដែលកំនត់ទៅតាមការប្រែប្រួលនៃរដូវកាល។ សំខាន់ គឺផ្អែកទៅលើគ្រួសារដែលប្រាប់ពីមុខរបរចំបងរបស់ពួកគេ គឺមានការពិបាកនឹងធ្វើការវាយតំលៃណាស់។ ចំពោះគ្រួសារដែលសាងសង់ផ្ទះរបស់គេនៅលើដីគោក តែងតែប្រាប់ថាមុខរបរចំបងរបស់ពួកគេ គឺជាអ្នកធ្វើស្រែ ទោះបីជាពួកគេទៅនេសាទយ៉ាងទៀងទាត់ ឬរៀងរាល់ថ្ងៃក៏ដោយ។ ចំណែកឯអ្នកដែលរស់នៅក្នុងផ្ទះដែលសង់លើទឹកអាចចំណាយពេលជាច្រើនរបស់ពួកគេ ទៅលើការធ្វើនេសាទ ក៏ប៉ុន្តែពួកគេប្រហែលជាអាចរកបានប្រាក់ចំណូលបន្ថែមច្រើនពីវាលស្រែលិចទឹក និង សកម្មភាពធ្វើកសិកម្មផ្សេងៗទៀតផងដែរ។

វិសាលភាពចំពោះគ្រួសារខ្លះដែលចូលរួមក្នុងការធ្វើនេសាទ ដូចជាប្រភពចំណូលចំបង តាមរយៈការចំណាយពេលជាអតិបរមារបស់ពួកគេ ហើយគ្រាន់តែសំរាប់បំរើនូវតំរូវការប្រើប្រាស់ប្រចាំថ្ងៃ ឬ សំរាប់ធានា និង ទប់ទល់នៅពេលដែលដំណាំខូចខាត) គឺពិបាកនឹងកំណត់ជាតួលេខឬចំនួនណាស់ពីព្រោះការចូលរួម និងការជំរុញទឹកចិត្តទាំងនោះមានការប្រែប្រួលផងដែរទៅតាមពេលវេលានិងទីកន្លែង។ លើសពីនេះទៅទៀត គ្រួសារទាំងអស់នោះ ជាធម្មតាបានចូលរួមក្នុងសកម្មភាពដែលទាក់ទងទៅនឹងការធ្វើនេសាទ សំរាប់រកប្រាក់ចំណូលបន្ថែម ទៀត និង សកម្មភាពសំរាប់ការចិញ្ចឹមជីវិតផ្សេងទៀត ដូចជាការធ្វើឧបករណ៍នេសាទ ការកែច្នៃត្រី ការទិញ លក់ត្រី និង ការចិញ្ចឹមត្រី។

សិទ្ធិ និង ការប្រើប្រាស់ធនធានធម្មជាតិជាសាធារណៈ គឺជាកត្តាមួយសំខាន់ដល់ការទ្រទ្រង់ក្នុង ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជន និង ជាផ្នែកមួយដ៏សំខាន់ផងដែរចំពោះយុទ្ធសាស្រ្តនៃការប្រកបរបរ ចិញ្ចឹមជីវិត ជាពិសេសចំពោះអ្នកដែលមានជំរើសតិចតួចក្នុងការប្រកបរបរចិញ្ចឹមជីវិត។ ការសិក្សាមួយដែលធ្វើ ឡើងដោយ Rab *et al.*, 2005 បានបង្ហាញថា ប្រជាជនច្រើនជាង ៨០% បានពឹងផ្អែកយ៉ាងខ្លាំងទៅលើការ ប្រមូលអុស និង ប្រមូលបន្លែដូចជាត្រកួន និងព្រលិត ជាដើមពីធនធានធម្មជាតិ។ ហើយប្រាក់ចំណូល ដែលបានមកពីសកម្មភាពទាំងនោះ អាចមានតំលៃប្រហែលជា២៦ដុល្លារអាមេរិចក្នុងមួយគ្រួសារក្នុងមួយឆ្នាំ ហើយចំនួននេះ អាចចាត់ទុកថាដូចជាច្រើនដែរ ពីព្រោះចំណូលសរុបប្រចាំឆ្នាំក្នុងមួយនាក់ត្រូវបានប៉ាន់ស្មានថាប្រហែលជា១៧២ដុល្លារអាមេរិចក្នុងមួយឆ្នាំ (សូមមើលខាងក្រោម)។ ទន្ទឹមនឹងនោះដែរ ចំនួននេះគឺមានចំនួនទាបខ្លាំងជាងចំណូលសរុប ប្រចាំឆ្នាំក្នុងមួយនាក់ដែលគិតជាថ្នាក់ជាតិប្រហែលជា ៣១១ ដុល្លារអាមេរិច នៅក្នុងឆ្នាំ ២០០៣ ។

**តើការនេសាទគឺជារបៀបរស់នៅមួយដែលគេចូលចិត្ត ឬក៏ជាជំរើសតែមួយគត់នៃការប្រកបរបរ ចិញ្ចឹមជីវិត?** ហេតុផលចំបងនៃការចូលរួមរបស់ប្រជាជនទៅក្នុងការធ្វើនេសាទគឺជាទំលាប់ ឬ កេរ្តិ៍តំណែលរបស់គ្រួសារ ហើយជាផ្នែកមួយនៃការរកម្ហូបអាហារតាមបែបបុរាណសំរាប់ប្រើប្រាស់ក្នុងផ្ទះ និង ផ្តល់ជាប្រភពនៃម្ហូប អាហារដែលមានតំលៃទាប។ ចំពោះគ្រួសារដែលរស់នៅឆ្ងាយពីបឹងទន្លេសាប អាចមានភាពងាយស្រួលក្នុងការ ផ្លាស់ប្តូរពីរបរនេសាទទៅមុខរបរផ្សេងទៀតជាច្រើន រីឯអ្នកដែលរស់នៅជិតតំបន់បឹងវិញ ពួកគេគ្មានលទ្ធភាពក្នុង ការផ្លាស់ប្តូរទេ។ វាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការទទួលស្គាល់អំពីការចាំបាច់នៃភាពសំបូរបែបនៃមុខរបរផ្សេងៗ និង ឱកាសការងារក្រៅពីការងារនេសាទ។ ហេតុដូច្នេះភាពសំបូរបែបនៃសកម្មភាពសំរាប់ចិញ្ចឹមជីវិត និង រកប្រាក់ចំណូល គឺជាយុទ្ធសាស្រ្តនៃការប្រកបរបរចិញ្ចឹមជីវិតសំខាន់មួយសំរាប់ប្រជាជនភាគច្រើនដែលរស់នៅជុំវិញបឹងទន្លេសាបដោយមិនគិតពីមុខរបរចំបង ភេទ អាយុ និង ការអប់រំឡើយ។

តួនាទីរបស់យេនឌ័រតាមបែបបុរាណ គឺមានការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រនៃការប្រកបរបរចិញ្ចឹមជីវិត។ ស្ត្រីនៅតែមានការទទួលខុសត្រូវចំបងចំពោះការងារនៅក្នុងផ្ទះ និងថែទាំកូនចៅ។ ចំណែកឯបុរសវិញ គឺធ្វើការនៅក្រៅផ្ទះដើម្បីរកប្រាក់ចំណូល និងរួមទាំងការធ្វើនេសាទផងដែរ។ ស្ត្រីមិនសូវចូលរួមក្នុងការងារធ្វើនេសាទទេ ប៉ុន្តែពួកគេដើរតួយ៉ាងសំខាន់នៅក្នុងការផ្គត់ផ្គង់ផលិតផលវារិជាត វារីវប្បកម្ម និងការថែរក្សារឬជួសជុលឧបករណ៍នេសាទ។ ក្នុងចំណោមគ្រួសារដែលមានស្ត្រីជាមេគ្រួសារ នេះគិតចំពោះអ្នកដែលរស់នៅជុំវិញបឹងទន្លេសាប) បានរៀបរាប់ថា ការងារចំបងរបស់ពួកគេគឺដូចគ្នាទៅនឹងការងារបុរសដែលជាមេគ្រួសារផងដែរ។ ការចូលរួមរបស់ស្ត្រីក្នុងការធ្វើនេសាទ អាចមានច្រើនជាងការពិតជាក់ស្តែងដែលត្រូវបានទទួលស្គាល់ដោយសង្គម ព្រោះភាគច្រើននៃសកម្មភាពរបស់ពួកគេដើម្បីផ្គត់ផ្គង់នូវភាពតំរូវការនៅក្នុងផ្ទះតែប៉ុណ្ណោះគឺ "គ្មានការទទួលស្គាល់ ឬភាពមើលមិនឃើញឡើយ"។ គេបានសង្កេតឃើញថា ចំពោះស្ត្រី នៅពេលដែលគេមានឱកាសនោះហុចអោយពួកគេទៅធ្វើនេសាទនៅតាមស្ទឹង ឬ ទន្លេ ដោយប្រើប្រាស់ឧបករណ៍មងតូចៗ ហើយជាញឹកញាប់គឺទៅជាមួយកូនរបស់គេ។

## វាយតំលៃលើធនធានជលផលនិងវារិជាត

ការវាយតំលៃធនធានជលផលនិងវារិជាតគឺជាដំណើរការមួយដែលមានភាពសាំញ៉ាំបំផុត។ គេអាចវាយ តំលៃតាមរយៈ "តំលៃប្រើប្រាស់" (Use Values) និង "តំលៃមិនប្រើប្រាស់" (Non-Use Values) (រូបភាព ទី១)។ បន្ថែមពីលើនេះ តំលៃប្រើប្រាស់អាចចែកចេញជា តំលៃប្រើប្រាស់ដោយផ្ទាល់ (Direct Use Values) តំលៃប្រើប្រាស់ដោយប្រយោល (Indirect Use Values) និង តំលៃដោយជ្រើសរើស (Option Values)។

ចំពោះ "តំលៃប្រើប្រាស់ដោយផ្ទាល់" គឺថាតំលៃទាំងនោះបានមកពីផលិតកម្ម ការប្រើប្រាស់ឬបរិភោគ និងការលក់នៃធនធាន ដូចជាតាមរយៈការធ្វើនេសាទ ការធ្វើកសិកម្ម ការប្រមូលអុស ព្រមទាំងការប្រើប្រាស់ ដែលមិនមែនជាម្ហូបអាហារ ដូចជា ថាមពល លំនៅដ្ឋានឬជំរក គមនាគមន៍ និងការធ្វើឱ្យមានឡើងវិញនូវអ្វី ដែលបានបាត់បង់ទៅហើយ។ ទោះជាយ៉ាងណាក៏ដោយ មាន "តំលៃប្រើប្រាស់ដោយប្រយោល គឺជាតំលៃដែល ទទួលបានមកពីនាទីនៃប្រព័ន្ធអេកូឡូស៊ី និងផ្តល់នូវសេវាកម្មផ្សេងៗទៀតដោយប្រពន្ធ័ធនធានវារិជាត ឧទាហរណ៍ ដូចជាការប្រើប្រាស់ព្រៃលិចទឹកដើម្បីជាជំរកត្រីពងនិងកន្លែងសំរាប់ភ្ញាស់ និងជាចំណីសត្វ ការរក្សាគុណភាពទឹក ការស្តុកនិងលំហូរនៃទឹក ការគ្រប់គ្រងទឹកជំនន់និងការពារខ្យល់ព្យុះ ការរក្សាជាម្ហូបអាហារ និងរក្សាឱ្យមានលំនឹងមីក្រូអាកាសធាតុ។ ចំណែកឯ "តំលៃដោយការជ្រើសរើស" គឺថាអាចទទួលបានផលប្រយោជន៍នៅពេលក្រោយ មកទៀតដូចជានៅរដូវបិទនេសាទរយៈពេលដ៏វែងមួយ។ ឧទាហរណ៍មួយនៃ "តំលៃមិនប្រើប្រាស់" គឺសំដៅ ទៅលើ "តំលៃមានស្រាប់" ដែលទទួលបានមកពីចំណេះដឹងនិងសេចក្តីសប្បាយរីករាយដែលផ្សារភ្ជាប់ជាមួយនឹង ការយល់ដឹងពីស្ថានភាពធនធានធម្មជាតិ ដោយភាពមានលក្ខណៈល្អប្រសើរ និង "តំលៃជាកេរ្តិ៍ " ដែលផ្សារភ្ជាប់ ជាមួយនឹងការពេញចិត្តដើម្បីបង្កើតឡើងនូវធនធានឱ្យមានភាពប្រសើរឡើងសំរាប់មនុស្សជំនាន់ក្រោយទៀត។ ម្យ៉ាងវិញទៀត តំលៃមិនប្រើប្រាស់ទាំងនោះ គឺពិបាកមើលឃើញ និងធ្វើការប៉ាន់ស្មានជាងតំលៃប្រើប្រាស់ ដូច្នេះហើយ ទើបគេមិនសូវយកមកពិនិត្យនិងពិចារណាក្នុងការងារសំរេចចិត្តនៃការគ្រប់គ្រងទេ។

វិធីសាស្ត្រមួយដើម្បីប៉ាន់ស្មានតំលៃប្រើប្រាស់ដោយផ្ទាល់ "សំរាប់ការប្រើប្រាស់" នៃធនធានជលផលនិង វារិជាត គឺតាមរយៈការស្ទង់ព័ត៌មាននៃប្រាក់ចំណូលសរុបរបស់គ្រួសារពីសកម្មភាពផ្សេងៗ។ ការប៉ាន់ស្មានទាំងនេះឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃធនធានទាំងនោះតាមរយៈការរកប្រាក់ចំណូលនិងភាពពឹងផ្អែកនៃការប្រកបរបរ ចិញ្ចឹមជីវិតរបស់ពួកគេដែលគឺតំលៃមួយជាក់ស្តែងបំផុតនៃតំលៃធនធានទាំងនោះ។ ដោយប្រើប្រាស់ទិន្នន័យដែល ដកស្រង់ចេញពីការស្ទង់ព័ត៌មានពីគ្រួសារដែលធ្វើឡើងដោយ Rab *et al*., (2005) តំលៃប្រើប្រាស់ដោយផ្ទាល់ នៃធនធាននៅជុំវិញបឹងទន្លេសាប និងធនធានវារិជាត ត្រូវបានប៉ាន់ស្មានដោយផ្អែកទៅលើ




រូបភាពទី ១: ប្រភេទផ្សេងៗនៃតំលៃដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធអេកូឡូស៊ីរបស់ធនធានវារិជាត នៅតំបន់បឹងទន្លេសាប



**តារាងទី១: ចំណូលប្រចាំឆ្នាំសរុប "ប៉ាន់ស្មាន" (000 ដុល្លារអាមេរិច) នៃគ្រួសារដែលពឹងផ្អែកទៅលើជលផលនៅក្នុងខេត្តប្រាំនៅជុំវិញបឹងទន្លេសាប**

| កំរិតចំណូល | ចំនួនគ្រួសារនេសាទ (000) | ចំណូលសរុបសំរាប់គ្រួសារទាំងអស់ (លានដុល្លារអាមេរិច) |
|---|---|---|
| ≤១000 | ១៥១ | ៧១ |
| ១00១ - ២000 | ៣៤ | ៤៤ |
| ២00១ - ៥000 | ១៨ | ៦0 |
| >៥000 | ៦ | ៤0 |
| សរុប | ២0៩ | ២១៥ |

របាយការណ៍ប្រាក់ចំណូល នៃគ្រួសារគំរូនៅក្នុងប្រភេទភូមិនេសាទ ភូមិនេសាទផងនិងធ្វើស្រែផង និង ភូមិធ្វើស្រែសុទ្ធ។ ការប៉ាន់ស្មាន ត្រូវបានបែងចែកដាច់ពីគ្នាផងដែរ ទៅតាមកំរិតនៃប្រាក់ចំណូល ដើម្បីចាប់យកនូវការបែងចែកនូវភោគទ្រព្យ និង ភាពមិនស្មើគ្នានៃប្រាក់ចំណូលដែលមានស្រាប់។

ដូចដែលបានបង្ហាញនៅក្នុងតារាងទី១គឺមានភាពខុសគ្នាយ៉ាងខ្លាំងរវាងចំណូលប្រចាំឆ្នាំជាមធ្យមនៃគ្រួសារ គំរូដែលមានកំរិតទាបជាងគេគឺ តូចជាង ១.000ដុល្លារអាមេរិច ហើយនឹងខ្ពស់ជាងគេបំផុតគឺ ច្រើនជាង ៥.000ដុល្លារអាមេរិច។ ការប៉ាន់ស្មានចំណូលសរុបសំរាប់គ្រួសារដែលរស់នៅដោយពឹងផ្អែកទៅលើធនធានជលផលនៅ ក្នុងខេត្តទាំងប្រាំគឺមានប្រហែលជា ២១៥លានដុល្លារអាមេរិច។ នេះបង្ហាញឱ្យឃើញថា ប្រាក់ចំណូលប្រចាំឆ្នាំក្នុងមួយនាក់គឺមានប្រហែលជា ១៧២ដុល្លារអាមេរិច ដោយផ្អែកទៅលើចំនួនប៉ាន់ស្មាននៃ ២0៩.000គ្រួសារ ដែលមានចំនួនសមាជិកគ្រួសារជាមធ្យម ៦នាក់ក្នុងមួយគ្រួសារ។

នៅពេលដែលពិនិត្យទៅលើចំណូលគ្រួសារទៅតាមកំរិតចំណូល មានគ្រួសារភាគច្រើន គឺថាច្រើនជាង ៧0% នៃគ្រួសារទាំងអស់រកប្រាក់ចំណូលប្រចាំឆ្នាំបានត្រឹមតែប្រហែលជា ៤៧0ដុល្លារអាមេរិចឬស្មើនឹង៧៨ដុល្លារអាមេរិចក្នុងមួយនាក់ (រូបភាព ទី២)។ ផ្ទុយគ្នាដែរ មានប្រហែលជា ១២%នៃគ្រួសារគំរូ (ដែលមានប្រាក់ចំណូលលើសពី ២.000 ដុល្លារអាមេរិចក្នុងមួយឆ្នាំ) ដែលមានស្ទើរតែពាក់កណ្តាលនៃចំណូលសរុបដុលនៃគ្រួសារទាំងអស់។ គ្រួសារដែលមានប្រាក់ចំណូលជាមធ្យមទាបជាង ១.000ដុល្លារអាមេរិច គឺប្រហែលជាអ្នកនេសាទជាលក្ខណៈ គ្រួសារឬទ្រង់ទ្រាយតូច ឬ សំរាប់តែគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិត និង កសិករដែលពឹងផ្អែកយ៉ាងខ្លាំង (ឬមិនទាំង ស្រុង) ទៅលើធនធានវារិជាតសំរាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។ រីឯអ្នកដែលមានប្រាក់ចំណូលខ្ពស់គឺ សំដៅទៅលើអ្នកនេសាទជាលក្ខណៈទ្រង់ទ្រាយមធ្យម និងម្ចាស់ឡូតិ៍នេសាទ។ ភាពខុសគ្នានៃប្រាក់ចំណូលរវាងគ្រួសារគំរូ គឺជាបញ្ហាមួយដ៏សំខាន់និងចំពោះមុខ ដែលចាំបាច់ត្រូវតែធ្វើការដោះស្រាយ។

នៅពេលដែលបូកបន្ថែមនូវតំលៃនៃជលផលសំរាប់ការប្រើប្រាស់ក្នុងផ្ទះ (ប្រហែលជា១៣លានដុល្លារអាមេរិច) និងតំលៃដោយផ្ទាល់របស់ធនធានកម្មសិទ្ធជាសាធារណៈផ្សេងៗទៀត (ប្រហែលជា៥លានដុល្លារអាមេរិច) ហើយតំលៃនៃការប្រើប្រាស់ផ្ទាល់សរុបដែលអាចបរិភោគបានមកពីបឹងទន្លេសាបគឺកើនឡើងទៅដល់២៣៣លាន ដុល្លារអាមេរិច។ នេះគួរអោយកត់សំគាល់ផងដែរថា ការសន្មត់ខ្លះៗត្រូវបានកំណត់ឡើងដើម្បីទទួលបាននូវ ការប៉ាន់ស្មានទាំងនេះ ហើយសំខាន់បំផុតនោះ គឺ គេគ្រាន់តែបង្ហាញពីតំលៃជា "អប្បបរមា" នៃធនធានវារិជាត ដែលបានមកពីបឹងទន្លេសាបតែប៉ុណ្ណោះ។ សារៈសំខាន់តំលៃនៃតំលៃមិនប្រើប្រាស់យ៉ាងច្រើននៃបឹងទន្លេសាប និង ប្រព័ន្ធអេកូឡូស៊ីនៃតំបន់ដីសើមទាំងឡាយ គឺចាំបាច់ត្រូវតែប្រមូលយកមក និង ពិភាក្សាដើម្បីរៀបចំគោល នយោបាយគ្រប់គ្រងធនធានធម្មជាតិមួយ ដើម្បីឆ្លុះ

បញ្ជាំងអំពីសារៈសំខាន់ដ៏ពិតប្រាកដមួយនៃធនធានទាំងនោះចំពោះការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ។

## វាយតំលៃលើធនធានជលផលនិងវារិជាត

ផ្ទុយទៅវិញ កត្តាជាច្រើនដែលប៉ះពាល់ដល់លទ្ធភាពនៃការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនគឺមាន ច្រើន។ មានការប្រឈមជាមួយនឹងបរិស្ថាន និងអេកូឡូស៊ី រួមមានដូចជាភាពងាយប្រែប្រួលរបស់ធម្មជាតិទៅ នឹងកំរិតភ្លៀងធ្លាក់ និង ទឹកជំនន់ ហើយនឹងពេលវេលានិងកំឡុងពេលនៃតំបន់លិចទឹក។ ទោះបីជាយ៉ាងណាក៏ ដោយ កត្តាទាំងនោះត្រូវបានធ្វើអោយមានប្រពលលក្ខណៈតាមរយៈសកម្មភាពរបស់មនុស្សជាច្រើនដូចជា ការសាងសង់ទំនប់ទឹក ការកាប់បំផ្លាញព្រៃឈើ និងការប្រើប្រាស់ជីគីមីឬថ្នាំសំលាប់សត្វល្អិតក្នុងការធ្វើការងារ កសិកម្ម និងការអភិវឌ្ឍន៍ដីធ្លី។ ទាំងនេះគឺជាផលប៉ះពាល់ដោយប្រយោល និងប៉ះពាល់ដោយផ្ទាល់ដែលបណ្តាលមកពី សកម្មភាពផ្សេងៗដូចជា ការនេសាទច្រើនហួសកំរិត និងការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់និងបំផ្លិចបំផ្លាញ មានឥទ្ធិពលយ៉ាងសំខាន់ទៅលើការប្រកបរបរចិញ្ចឹមជីវិតនៃសហគមន៍នៅតំបន់បឹងទន្លេសាប។

ផ្ទុយទៅវិញ មានកត្តាសេដ្ឋកិច្ចសង្គមផ្សេងៗទៀតផងដែរដែលផ្តល់ផលប៉ះពាល់ទៅលើការប្រកបរបរ ចិញ្ចឹមជីវិតនៅជុំវិញបឹងទន្លេសាប។ ក្នុងនោះគេធ្វើការសន្និដ្ឋានទៅលើការគាបសង្កត់ដែលបណ្តាលមកពីកំនើនប្រជាជន ទំនាស់រវាងអ្នកពាក់ព័ន្ធទៅលើសិទ្ធិនិងការប្រើប្រាស់នៃធនធាន ភាពមិនសមាមាត្រនៃការបែងចែក ប្រាក់ចំណូល និងវិសមភាពនៃយេនឌ័រ។ សហគមន៍ដែលពឹងផ្អែកទៅលើធនធានវារិជាតមានភាពងាយនឹង ទទួលរងយ៉ាងខ្លាំងអំពីការផ្លាស់ប្តូរនៃផលិតភាពធម្មជាតិនៃបឹងទន្លេសាប ហើយនិងការផ្លាស់ប្តូរនៃការគ្រប់គ្រង និងស្ថាប័ន ដូចជាកំណែទំរង់គោលនយោបាយវិស័យជលផល ដែលអាចនាំមកនូវឱកាសក៏ដូចជាបង្កើតនូវបញ្ហាថ្មីមួយទៀតដែរ។ ជាសរុប ភាពងាយទទួលរងគ្រោះនៃប្រជាជនដែលពឹងផ្អែកទៅលើប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប គឺត្រូវបានពង្រឹងបន្ថែមទៀត ដោយហេតុថាតំលៃភាគច្រើននៃប្រពន្ធ័អេកូឡូស៊ីនេះនៅតែមានភាពមិនសូវល្អនៅឡើយ។ ការយកមកគិតនូវតំលៃទាំងនោះ គឺអាចជួយបង្កើននូវការយល់ដឹងថែមទៀត ហើយនឹងអាចជួយ ចូលរួមដល់ការពង្រឹងនូវការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនផងដែរ។

**តើចំលើយអ្វី ដែលចាំបាច់ត្រូវតែដោះស្រាយចំពោះប្រពន្ធ័អេកូឡូស៊ី សង្គម សេដ្ឋកិច្ច និង បញ្ហាការគ្រប់គ្រង ជាមួយនឹងធនធានវារិជាតនិងប្រពន្ធ័អេកូឡូស៊ីនៃបឹងទន្លេសាប?**




រូបភាពទី២: ការបែងចែកជាភាគរយនៃចំនួនគ្រួសារនិងការប៉ាន់ស្មានចំណូលសរុបប្រចាំឆ្នាំតាមកំរិតប្រាក់ចំណូល (ប៉ាន់ស្មានសំរាប់ប្រាំខេត្ត)



តំរូវការនៃការស្រាវជ្រាវមួយចំនួន និង ការពិចារណាលើគោលនយោបាយផ្សេងៗត្រូវបានលើកឡើងមក មានដូចខាងក្រោមនេះ:

- បង្កើននូវចំណេះដឹងអំពីប្រពន្ធ័អេកូឡូស៊ី ឧទាហរណ៍ទំនាក់ទំនងរវាងការបាត់បង់ជំរក និង ព្រៃលិចទឹក ហើយនឹងផលប៉ះពាល់ដល់សុខភាពនៃការ ធ្វើនេសាទនិងភាពឱ្យផលឬផលិតភាពនៃបឹងទន្លេសាប។
- ការយល់ដឹងនូវការផ្លាស់ប្តូរជានិច្ចនៃសង្គម (social dynamics) រវាងអ្នកពាក់ពន្ធ័ រួមមានអ្នកមកពីកន្លែង ផ្សេងៗ អ្នកនេសាទទៅតាមរដូវ និង អ្នកនេសាទ ដែលមានជនជាតិផ្សេងៗគ្នា ដើម្បីដោះស្រាយបញ្ហាដែល ទាក់ទងទៅនឹងការប្រើប្រាស់ឧបករណ៍នេសាទបំផ្លិចបំផ្លាញនិងខុសច្បាប់ ជំលោះរវាងអ្នកពាក់ពន្ធ័ សិទ្ធិក្នុងការប្រើប្រាស់ធនធាន ទីផ្សារនិងប្រពន្ធ័ឥណទាន។
- បង្កើនការយល់ដឹងអំពីរភាពខុសគ្នានៃប្រាក់ចំណូលដែលមានស្រាប់ ក្នុងចំណោមគ្រួសារទាំងនោះ ហើយនឹងធ្វើឱ្យប្រសើរឡើងលើការប៉ាន់ស្មាននៃតំលៃសេដ្ឋកិច្ចសរុបរបស់ធនធានជលផលនៃបឹងទន្លេសាប និង ប្រពន្ធ័អេកូឡូស៊ីនៃវារិជាត តាមរយៈការរួមបញ្ចូល នូវតំលៃទាំងអស់នៃតំលៃប្រើប្រាស់ និង តំលៃមិនប្រើប្រាស់។
- ពិនិត្យទៅលើជំរើសផ្សេងទៀត និង យុទ្ធសាស្រ្តនៃការប្រកបរបរចិញ្ចឹមជីវិត ដើម្បីវាយតំលៃផលប៉ះពាល់នៃសកម្មភាពនានា និង ជំរើសផ្សេងៗនៃគោលនយោបាយស្តីពីសុវត្ថិភាពស្បៀងអាហារ និង គុណភាពនៃជីវិតរស់នៅ។
- ការយល់ដឹងអំពីតួនាទីនិងការចូលរួមរបស់ស្រ្តីទៅក្នុងការបង្កើតប្រាក់ចំណូល ដើម្បីទ្រទ្រង់ដល់ការប្រកបរបរចិញ្ចឹមជីវិត ក៏ដូចជាក្នុងការគ្រប់គ្រង និង ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត។
- ពិនិត្យទៅលើប្រសិទ្ធភាពនៃកំណែទំរង់គោលនយោបាយជលផលនៅពេលថ្មីៗនេះ ជាពិសេសគឺសំដៅទៅលើការបែងចែកផលប្រយោជន៍ និង បញ្ហានៃការរាប់បញ្ចូលឬមិនបញ្ចូលនៃអ្នកពាក់ពន្ធ័ ដើម្បីធ្វើការកែសំរួលឱ្យបានសមរម្យចាំបាច់មួយ នៅក្នុងការរៀបចំស្ថាប័ន និងរចនាសម្ព័ន្ធនៃការគ្រប់គ្រង ឬ អភិបាលកិច្ច។

សេចក្តីសង្ខេបនេះ បានរៀបរាប់អំពីសេដ្ឋកិច្ចសង្គម និង យុទ្ធសាស្រ្តនៃការប្រកបរបរចិញ្ចឹមជីវិតរបស់ សហគមន៍ដែលរស់នៅក្នុង និង ជុំវិញបឹងទន្លេសាបដែលពឹងផ្អែកលើការធ្វើនេសាទ និង សង្ខេបពីលទ្ធផលនៃការសិក្សាស្រាវជ្រាវថ្មីៗនេះមួយចំនួន ហើយផ្តល់នូវផ្នែកមួយសំរាប់ការប៉ាន់ស្មានតំលៃសេដ្ឋកិច្ចសរុបមួយ ដែលបានមកពីប្រពន្ធ័អេកូឡូស៊ីនៃធនធានវារិជាត។ តាមទ្រឹស្តីការវាយតំលៃលើការប្រកបរបរចិញ្ចឹមជីវិតនិងដំណើរការ នៃការវាយតំលៃគួរតែមានការទំនាក់ទំនងរវាងគ្នានឹងគ្នាទៅវិញទៅមក ឬ អន្តរទំនាក់ទំនង ពីព្រោះការយល់ដឹង អំពីយុទ្ធសាស្រ្តនៃការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនផ្តល់នូវផ្នែកមួយដ៏សំខាន់ដើម្បីឆ្ពោះទៅរកការវាយតំលៃ ពេញលេញមួយនូវតំលៃសរុបនៃធនធានធម្មជាតិ។

ជាលទ្ធផល ការពិចារណានានាទៅលើការប្រកបរបរចិញ្ចឹមជីវិតនិងតំលៃនៃប្រពន្ធ័អេកូឡូស៊ីត្រូវតែធ្វើជាបន្តបន្ទាប់គ្នា ប្រសិនបើយើងរៀបចំគោលនយោបាយនៃការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាពមួយយ៉ាង ពិតប្រាកដដើម្បីលើកកំពស់លទ្ធភាពនៃការប្រកបរបរចិញ្ចឹមជីវិតនៅតំបន់បឹងទន្លេសាប។

## ឯកសារយោង

***Ahmed, M., Hap, N., Vuthy, L., and Tiongco, M. 1998***. Socio-economic assessment of freshwater capture fisheries of Cambodia: Report on a household survey. Mekong River Commission, Phnom Penh, Cambodia. 186 p.

***Baran, E. 2005***. Cambodian inland fisheries: facts, figures and context. WorldFish Centre, and Inland Fisheries Research and Development Institute, Phnom Penh, Cambodia. 49p.

***DoF, 2004***. Statistics of Fisheries Production 1980 to 2003. Department of Fisheries, Ministry of Agriculture, Forestry and Fisheries. Cambodia.

***Hap, N., Seng, L. and Chuenpagdee, R. 2006***. Socioeconomics and Livelihood Values of Tonle Sap Lake Fisheries. Inland Fisheries Research and Development Institute (IFREDI), Phnom Penh, Cambodia. (Available at www.ifredi.org).

***Keskinen, M. 2003***. The Great Diversity of Livelihoods? - Socio-economic survey of the Tonle Sap Lake. WUP-FIN Socio-Economic Studies on Tonle Sap 8, MRCS/WUP-FIN, Phnom Penh.